# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសុខាភិបាល**

លេខ ៣៤៦ អបស

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១០

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ជម្រាបជូន

## លោក លោកស្រីអាជីវករលក់ដុំបារីនិងរាយទាំងអស់

**កម្មវត្ថុ :** ការលក់បារីដែលមានសារព្រមានសុខភាព ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងសុខាភិបាលសង្កេតឃើញថា បារីមួយចំនួនដែលកំពុងបានដាក់តាំងលក់នៅលើទីផ្សារពុំទាន់មានការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារីស្របតាមអនុក្រឹត្យលេខ១៨១អនក្រ បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី និងសេចក្តីប្រកាសរបស់ក្រសួងសុខាភិបាល លេខ ១១៦២ អបស ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការអនុវត្តន៍ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ។

ដូចនេះក្រសួងសុខាភិបាលជម្រាបជូនលោក លោកស្រីអាជីវករលក់ដុំបារីនិងរាយទាំងអស់ ទទួលទិញ និងលក់បារី ដែលមានសារព្រមានសុខភាពលើកញ្ចប់បារីតែប៉ុណ្ណោះ ។ ចំពោះបារីណាដែលពុំមានសារព្រមានសុខភាព គឺជាផលិតផលពុំស្របច្បាប់ឡើយ ។ ចំពោះក្រុមហ៊ុននាំចូល និងផលិតករក្នុងស្រុក ដែលមិនអនុវត្តន៍តាមគោលការណ៍របស់រាជរដ្ឋាភិបាលដូចមានចែងខាងលើនេះ ក្រសួងសុខាភិបាលបានធ្វើការព្រមានទៅតាមច្បាប់ជាធរមានជាបន្តបន្ទាប់ហើយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំសង្ឃឹមថាលោក លោកស្រីអាជីវករលក់បារីដុំនិងរាយទាំងអស់ ទទួលទិញ និងលក់បារីដែលមានសារព្រមានសុខភាពលើកញ្ចប់បារីឱ្យបានត្រឹមត្រូវ ។

សូមលោក លោកស្រីអាជីវករទាំងអស់ទទួលនូវការរាប់អានអំពីខ្ញុំ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

វេជ្ជ. អ៊ឹង-ភីរុន

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គណៈកម្មាការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់

-ខុទ្ទកាល័យក្រសួងសុខាភិបាល

-ក្រុមហ៊ុនថ្នាំជក់

"ដើម្បីជូនជ្រាប"

-បណ្តាអាជីវករលក់ដុំបារីនិងរាយ" ដើម្បីអនុវត្ត"

-ឯកសារ

ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វុក្ខវិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨២៦ ០៣៤/៨២៦ ៨៤១ ទូរស័ព្ទៈ (៨៥៥-២៣) ៧២២ ៩៣៣